# ជួយយើងដឹងពីអ្នកជម្ងឺរបស់យើងកាន់តែច្រើន

## សំណួរអំពីការប្រមូលព័ត៌មានពូជសាសន៍ និង ជាតិពន្ធុរបស់អ្នកជម្ងឺ



### ហេតុអ្វីក៏មានការសួរសំណួរទាំងនេះ?

ឥឡូវនេះ យើងកំពុងប្រមូលព័ត៌មានពូជសាសន៍ និង ជាតិពន្ធុពីអ្នកជម្ងឺរបស់យើងទាំងអស់ដើម្បីជួយយើងដឹងពីពួកគេឱ្យកាន់តែច្រើន ។ យើងអាចបំពេញតម្រូវការរបស់សហគមន៍ដែលយើងបម្រើកាន់តែប្រសើរ ប្រសិនបើយើងដឹងពីអ្នកជម្ងឺរបស់យើង វប្បធម៌របស់ពួកគេ និង ភាសារបស់ពួកគេ ។ ព័ត៌មាននេះនឹងត្រូវបានប្រើប្រាស់ដើម្បីឱ្យប្រាកដថាអ្នកជម្ងឺទាំងអស់កំពុងទទួលការថែទាំដ៏សមស្របមានគុណភាពខ្ពស់បំផុតប៉ុណ្ណោះ ។

### ហេតុអ្វីខ្ញុំត្រូវបានសួរសំណួរទាំងនេះ?

យើងកំពុងប្រមូលព័ត៌មាននេះពីអ្នកជម្ងឺទាំងអស់ ។ នេះនឹងជួយយើងពិនិត្យមើលពីភាពខុសគ្នាលើសុខភាពក្នុងចំណោមប្រជាជនផ្សេងៗគ្នា ។ យើងអាចកាត់បន្ថយភាពខុសគ្នាទាំងនោះដោយការធ្វើឱ្យប្រាកដថាអ្នកជម្ងឺទាំងអស់ទទួលបាននូវគុណភាពនៃការថែទាំដូចគ្នា ។

### តើសំណួរទាំងនេះត្រូវបានសួរនៅមន្ទីពេទ្យដទៃទៀតដែរឬទេ?

មានបទបញ្ញារបស់រដ្ឋថ្មីមួយចំនួនដែលតម្រូវឱ្យមន្ទីពេទ្យទាំងអស់នៅក្នុងរដ្ឋម៉ាសាជូសេត ប្រមូលព័ត៌មាននេះ ។ យើងកំពុងប្រមូលព័ត៌មាននេះ ជាផ្នែកមួយនៃកិច្ចខំប្រឹងប្រែងទូទាំងរដ្ឋ ដើម្បីលើកកម្ពស់សុខភាពរបស់យើងទាំងអស់គ្នា ។



### តើពូជសាសន៍ និង ជាតិពន្ធុរបស់ខ្ញុំទាក់ទងនឹងសុខភាពរបស់ខ្ញុំដូចម្តេច?



ការសិក្សាបានបង្ហាញថាមានភាពខុសគ្នាលើសុខភាពក្នុងចំណោមក្រុមពូជសាសន៍ និង ជាតិពន្ធុផ្សេងៗ ។ យើងមិនដឹងពីបុព្វហេតុអ្វីដែលនាំឱ្យមានភាពខុសគ្នាទាំងនេះទេ ហើយយើងត្រូវការសិក្សាបន្ថែមទៀតអំពីពួកវា ។ យើងអាចធ្វើការដើម្បីលុបបំបាត់ភាពខុសគ្នាទាំងនេះដោយការធ្វើឱ្យប្រាកដថាមនុស្សទាំងអស់ទទួលបាននូវគុណភាពនៃការថែទាំដូចគ្នា ។

### តើព័ត៌មាននេះនឹងត្រូវបានប្រើប្រាស់ដូចម្តេច?

យើងនឹងប្រើប្រាស់ព័ត៌មានពូជសាសន៍ និង ជាតិពន្ធុដែលយើងប្រមូលពីអ្នកជម្ងឺទាំងអស់ដើម្បីពិនិត្យមើលប្រសិនបើមានភាពខុសគ្នាលើសុខភាពក្នុងចំណោមក្រុមមនុស្សផ្សេងៗគ្នា ។ នេះនឹងជួយយើងឱ្យប្រាកដថាយើងផ្តល់នូវគុណភាពនៃការថែទាំដូចគ្នាទៅកាន់មនុស្សទាំងអស់ ។ យើងនឹងប្រើប្រាស់ព័ត៌មាននេះផងដែរដើម្បីយល់ពីតម្រូវការរបស់ប្រជាជនដែលយើងបម្រើ និង ប្រាកដថាមនុស្សទាំងនោះទទួលការថែទាំដែលសមស្របទៅតាមវប្បធម៌ ។

គោលបំណងរបស់យើងគឺដើម្បីបំពេញតម្រូវការរបស់អ្នកជម្ងឺទាំងអស់ដែលយើងបម្រើ ។ យើងអាចបំពេញតម្រូវការនេះដោយការផ្តល់នូវសេវាបកប្រែ, ផ្តល់ជូនអ្នកជម្ងឺនូវព័ត៌មានដែលបានបកប្រែជាភាសាផ្សេងៗ និង ប្រាកដថាបុគ្គលិករបស់យើងផ្តល់នូវការថែទាំសមស្របទៅតាមវប្បធម៌ ។

### ចុះប្រសិនបើខ្ញុំមិនចង់ចែករំលែកព័ត៌មាននេះ?

នេះគឺជាការសម្រេចចិត្តរបស់លោកអ្នក ប្រសិនបើលោកអ្នកចង់ចែករំលែកព័ត៌មាននេះ ។ យើងប្រមូលព័ត៌មាននេះគឺដើម្បីជួយយើងដឹងពីអ្នកជម្ងឺដែលយើងបម្រើឱ្យកាន់ច្រើនប៉ុណ្ណោះ ហើយវានឹងមិនប៉ះពាល់ដល់ការថែទាំ ឬ សេវាកម្មដែលលោកអ្នកទទួលឡើយ ។



**លើកកម្ពស់សុខភាព**
**របស់យើងទាំងអស់គ្នា**